# កញ្ចប់ប្រាក់ឧបត្ថម្ភគ្រួសារ

កញ្ចប់ប្រាក់ឧបត្ថម្ភគ្រួសាររបស់រដ្ឋាភិបាលមានបំណងជួយបង្កើនប្រាក់ចំណូលសម្រាប់គ្រួសារដែលមានប្រាក់ចំណូលទាប ឬមធ្យមហើយមានកូនក្នុងបន្ទុក។ ការផ្លាស់ប្តូរចំពោះកញ្ចប់ប្រាក់ឧបត្ថម្ភគ្រួសារបានចូលជាធរមានចាប់ពីថ្ងៃទី 1 ខែកក្កដាតទៅ។ ខាងក្រោមនេះជាព័ត៌មានលម្អិតមួយចំនួនអំពីការផ្លាស់ប្តូរនេះ។ ៖

## ប្រាក់ឧបត្ថម្ភសម្រាប់បង់ថ្លៃថាមពលនៅរដូវរងារ

ប្រាក់ឧបត្ថម្ភសម្រាប់បង់ថ្លៃថាមពលនៅរដូវរងារជួយមនុស្សចាស់ និងអ្នកដែលទទួលប្រាក់ឧបត្ថម្ភពីរដ្ឋឲ្យអាចកម្តៅផ្ទះរបស់ពួកគេបាននៅរដូវរងារ។ យើងនឹងបង់ថ្លៃថាមពលនេះចាប់ពីថ្ងៃទី 1 ខែកក្កដា ដល់ថ្ងៃទី 29 ខែកញ្ញានៅឆ្នាំនេះ ហើយចាប់ពីថ្ងៃ ទី 1 ខែឧសភា ដល់ថ្ងៃទី 1 ខែតុលា ចាប់ពីឆ្នាំ 2019 តទៅ។ អ្នកនៅលីវនឹងទទួលប្រាក់ឧបត្ថម្ភចំនួន 20.46 ដុល្លាក្នុងមួយសប្តាហ៍ ហើយអ្នកមានប្តី ឬប្រពន្ធ ឬអ្នកដែលមានកូនក្នុងបន្ទុកនឹងទទួលបានប្រាក់ឧបត្ថម្ភសម្រាប់បង់ថ្លៃថាមពលចំនួន 31.82 ដុល្លា ក្នុងមួយសប្តាហ៍ ។ អ្នកទាំងឡាយដែលមានសិទ្ធិទទួលប្រាក់ឧបត្ថម្ភនេះនឹងទទួលបានប្រាក់ឧបត្ថម្ភសម្រាប់បង់ថ្លៃថាមពលនៅ រដូវរងារជាស្វ័យប្រវត្តិ។

## ប្រាក់ឧបត្ថម្ភថ្មីសម្រាប់គ្រួសារមានកូនតូច

ប្រាក់ឧបត្ថម្ភថ្មីសម្រាប់គ្រួសារមានកូនតូចដើម្បីជួយក្រុមគ្រួសារណូវ៉ែលហ្សេឡង់ទាំងអស់ដែលមានកូនកើត (ឬនឹងកើត) នៅ ឬក្រោយថ្ងៃទី 1 ខែកក្កដា ឆ្នាំ2018។ គ្រួសារទាំងនេះនឹងទទួលបានប្រាក់ឧបត្ថម្ភចំនួន 60.00 ដុល្លាក្នុងមួយសប្តាហ៍សម្រាប់កូន និមួយៗ រហូតដល់ពួកគេមានអាយុមួយឆ្នាំ ហើយសម្រាប់គ្រួសារដែលមានប្រាក់ចំណូលទាបរហូតដល់កូនអាយុបីឆ្នាំ។

## ប្រាក់ឥណទានពន្ធសម្រាប់ជួយគ្រួសារ

ប្រាក់ឥណទានពន្ធសម្រាប់ជួយគ្រួសារបានកើនឡើងចាប់ពីថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2018។ អត្រាសម្រាប់កូនច្បងបានកើនឡើងដល់ 113.00 ដុល្លាក្នុងមួយសប្តាហ៍ ហើយអត្រាសម្រាប់កូនផ្សេងទៀតបានកើនឡើងដល់ 91.25 ដុល្លាក្នុងមួយសប្តាហ៍។

ការផ្លាស់ប្តូរចំពោះប្រាក់ឥណទានពន្ធសម្រាប់ជួយគ្រួសារមានន័យថាប្រាក់ចំណូលរបស់អ្នកមានសិទ្ធិទទួលនឹងកើនឡើង។ ការផ្លាស់ប្តូរនេះអាចប៉ះពាល់ដល់ប្រាក់ឧបត្ថម្ភផ្សេងៗទៀតរបស់ពួកគេ ដូចជាប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់ជួលផ្ទះ ឬប្រាក់ឧបត្ថម្ភបន្ថែមបណ្តោះអាសន្ន ឬប្រាក់ចំណូលទាក់ទងនឹងការជួលផ្ទះរបស់ពួកគេ។

## ប្រាក់ឧបត្ថម្ភកូនកំព្រា ឬកូនដែលគ្មានការទំនុកបម្រុង

អ្នកដែលទទួលប្រាក់ឧបត្ថម្ភកូនកំព្រា ឬកូនដែលគ្មានការទំនុកបម្រុងសម្រាប់កុមារដែលស្ថិតក្នុងការថែទាំរបស់ពួកគេ បានកើនឡើង ហើយនិងប្រាក់ឧបត្ថម្ភថ្មីសម្រាប់ទិញខោអាវថ្មីសម្រាប់កូននិមួយៗដែលពួកគេមើលថែទាំ។

### ព័ត៌មានផ្សេងទៀត

មានគ្រួសារមួយចំនួនតូចនឹងទទួលបានប្រាក់តិចជាងមុនតាមរយ:កញ្ចប់ប្រាក់ឧបត្ថម្ភគ្រួសារ ដោយសារស្ថានភាពពិសេសរបស់ ពួកគេ។ យើងនឹងបង់ប្រាក់ឧបត្ថម្ភអន្តរកាលជូនដល់ពួកគេដើម្បីឲ្យចំនួនប្រាក់ដែលពួកគេទទួលពីយើងនឹងរក្សានៅដដែល រហូតដល់មានការប្រែប្រួលសម្រាប់ពួកគេ ឬសម្រាប់រយ:ពេលរហូតដល់មួយឆ្នាំ។ ការផ្លាស់ប្តូរនៃប្រាក់ឧបត្ថម្ភរបស់អ្នកមានសិទ្ធិទាំងអស់នេះនឹងធ្វើឡើងដោយស្វ័យប្រវត្តិ។

### ពេលដែលត្រូវបើកប្រាក់ឧបត្ថម្ភដែលបានតម្លើង

ការបើកប្រាក់លើទីមួយនៅខែកក្កដាគឺជាការបើកជូនតែមួយចំណែកតែប៉ុណ្ណោះ។ ការបើកប្រាក់ឧបត្ថម្ភលើកទីពីរគឺជាការបើក ប្រាក់គ្រប់ចំនួន។ នេះគឺដោយសារយើងបើប្រាក់ឧបត្ថម្ភឲ្យអ្នកមានសិទ្ធិទទួលសម្រាប់សប្តាហ៍ដែលទើបតែបានកន្លងទៅ (ឬក៏ពីរសប្តាហ៍សម្រាប់ប្រាក់សោធននិវត្តណូវ៉ែលហ្សេឡង់)។ ដោយសារថ្ងៃទី1 ខែកក្កដាគឺជារយ:ពេលពាក់កណ្តាលនៃអំឡុងពេលបើក ប្រាក់នេះ អ្នកមានសិទ្ធិទទួលនឹងមិនអាចទទួលបានប្រាក់ឧបត្ថម្ភពេញនៅពេលបានទទួលប្រាក់ឧបត្ថម្ភលើកទីមួយនៅខែកក្កដា នោះទេ។

ALLA123-KHMER

Work and Income
Te Hiranga Tangata
A service of the Ministry of Social Development

**សម្រាប់ព័ត៌មានបន្ថែម**

- មនុស្សចាស់ សូមហៅទូរស័ព្ទទៅលេខ - 0800 552 002
- សំណួរទូទៅសម្រាប់អ្នកដែលមានអាយុក្រោម 65ឆ្នាំ - 0800 559 009